មេរៀនទី២

# តើព្រះទ្រង់ជាអ្នកណា ?

*តើព្រះពិតទ្រង់ជាអ្នកណា ហើយព្រះនាមទ្រង់ជាអ្វី? (១, ២)*

*តើទ្រង់មានរូបកាយបែបណា? (៣)*

*តើអ្វីជាគុណសម្បត្តិដ៏អស្ចារ្យរបស់ទ្រង់? (៤)*

*តើយើងត្រូវប្រើបដិមាករនិងសញ្ញាក្នុងការថ្វាយបង្គំទ្រង់ឬទេ? (៥)*

*តើរបៀបពីរយ៉ាងអ្វីដែលយើងអាចរៀនអំពីព្រះ? (៦)*



១. មនុស្សថ្វាយបង្គំរបស់ជាច្រើន ។ ប៉ុន្តែព្រះគម្ពីរប្រាប់យើងថា មានព្រះ**ពិត**តែមួយអង្គប៉ុណ្ណោះ ។ ទ្រង់បានបង្កើតរបស់សព្វសារពើក្នុងស្ថានសួគ៌និងលើផែនដី ។ ពីព្រោះទ្រង់បានប្រទានជីវិតដល់យើង យើងគួរថ្វាយបង្គំតែទ្រង់មួយអង្គប៉ុណ្ណោះ ។—កូរិនថូសទី១ ៨:៥, ៦; វិវរណៈ ៤:១១

២. ព្រះមានឋានន្តរជាច្រើន ប៉ុន្តែទ្រង់មានព្រះនាមតែមួយប៉ុណ្ណោះ ។ ព្រះនាមនោះគឺ**យេហូវ៉ា** ។ ក្នុងព្រះគម្ពីរភាគច្រើន ព្រះនាមនៃព្រះបានត្រូវគេដកចេញ ហើយយកឋានន្តរ **ព្រះអម្ចាស់** ឬ**ព្រះ**មកប្រើជំនួសវិញ ។ ប៉ុន្តែពេលដែលព្រះគម្ពីរបានត្រូវសរសេរឡើងជាដំបូង នោះព្រះនាមយេហូវ៉ាគឺឃើញមាននៅក្នុងព្រះគម្ពីរប្រហែល៧.០០០ដង !—និក្ខមនំ ៣:១៥; ទំនុកដំកើង ៨៣:១៨

៣. ព្រះយេហូវ៉ាទ្រង់មានរូបកាយ ប៉ុន្តែមិនមែនដូចរូបកាយរបស់យើងទេ ។ ព្រះគម្ពីរប្រាប់ថា «ព្រះទ្រង់

ជាវិញ្ញាណ» ។ (យ៉ូហាន ៤:២៤) វិញ្ញាណគឺជាជីវិតមួយប្រភេទដែលខ្ពស់ជាងជីវិតមនុស្សយើងឆ្ងាយណាស់ ។ ឥតមានមនុស្សណាដែលបានឃើញព្រះឡើយ ។ ព្រះយេហូវ៉ាទ្រង់គង់នៅក្នុងស្ថានសួគ៌ ប៉ុន្តែទ្រង់អាចទតឃើញអ្វីៗទាំងអស់ ។ (ទំនុកដំកើង ១១:៤, ៥; យ៉ូហាន ១:១៨) ប៉ុន្តែ ចុះអ្វីទៅជាវិញ្ញាណបរិសុទ្ធ ? វិញ្ញាណបរិសុទ្ធមិនមែនជាបុគ្គលមួយរូបដូចព្រះនោះទេ តែជាសកម្មពលរបស់ព្រះ ។—ទំនុកដំកើង ១០៤:៣០

*យើងរៀនអំពីព្រះពីរបស់បង្កើតនិងពីព្រះគម្ពីរ*

៤. ព្រះគម្ពីរបង្ហាញឲ្យយើងឃើញនូវបុគ្គលិកលក្ខណៈនៃព្រះយេហូវ៉ា ។ ហើយបង្ហាញថាគុណសម្បត្តិដ៏អស្ចារ្យរបស់ទ្រង់ គឺសេចក្ដីស្រឡាញ់ យុត្តិធម៌ ប្រាជ្ញា និងតេជានុភាព ។ (ចោទិយកថា ៣២:៤; យ៉ូប ១២:១៣; អេសាយ ៤០:២៦; យ៉ូហានទី១ ៤:៨) ព្រះគម្ពីរប្រាប់យើងថា ព្រះទ្រង់ក៏មានសេចក្ដីមេត្តាករុណា សប្បុរស អត់ឱនទោស សទ្ធា និងអត់ធ្មត់ដែរ ។ យើងប្រៀបដូចជាកូនដែលចេះស្ដាប់បង្គាប់ គួរតែខំត្រាប់តាមទ្រង់ ។—អេភេសូរ ៥:១, ២

៥. តើយើងត្រូវក្រាបខ្លួនឬអធិស្ឋានដល់បដិមាករ រូបឬសញ្ញាក្នុងពេលយើងថ្វាយបង្គំឬ ? ទេ ! (និក្ខមនំ ២០:៤, ៥) ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា យើងត្រូវតែថ្វាយបង្គំទ្រង់ប៉ុណ្ណោះ ។ ទ្រង់នឹងមិនឲ្យអ្នកណាមួយឬរបស់ណាមួយមកយកចំណែកសិរីល្អនៃទ្រង់ឡើយ ។ បដិមាករឥតមានឥទ្ធិឬទ្ធិជួយយើងបានទេ ។—ទំនុកដំកើង ១១៥:៤-៨; អេសាយ ៤២:៨

៦. តើតាមរបៀបណាដែលយើងអាចស្គាល់ព្រះឲ្យបានច្បាស់ថែមទៀត ? វិធីមួយគឺដោយសង្កេតមើលរបស់ដែលទ្រង់បានបង្កើតមក ហើយសញ្ជឹងគិតអំពីអ្វីៗដែលរបស់ទាំងនេះប្រាប់យើង ។ របស់ដែលព្រះបានបង្កើតមក បង្ហាញយើងថា ទ្រង់មានតេជានុភាពនិងប្រាជ្ញាដ៏ខ្លាំងក្លា ។ យើងឃើញសេចក្ដីស្រឡាញ់នៃទ្រង់ក្នុងអស់ទាំងរបស់ដែលទ្រង់បានបង្កើតមក ។ (ទំនុកដំកើង ១៩:១-៦; រ៉ូម ១:២០) វិធីម្យ៉ាងទៀតដែលយើងអាចរៀនអំពីព្រះគឺដោយសិក្សាព្រះគម្ពីរ ។ ក្នុងព្រះគម្ពីរ ទ្រង់មានបន្ទូលប្រាប់យើងរឹតតែច្រើនថែមទៀត ថាទ្រង់ជាព្រះបែបណា ។ ទ្រង់ក៏មានបន្ទូលប្រាប់យើងដែរ អំពីគោលបំណងរបស់ទ្រង់ និងអំពីអ្វីដែលទ្រង់ចង់ឲ្យយើងប្រព្រឹត្ត ។—អេម៉ុស ៣:៧; ធីម៉ូថេទី២ ៣:១៦, ១៧

